សុន្ទរកថារបស់ **ឯកឧត្តម លោក ម៉ាសាហ៊្វូមី គូរ៉ូគី**

ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំកម្ពុជា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន

០១ វិច្ឆិកា ២០១២

- **សូមគោរព កញ្ញា អាកេមិ តាកាហាហ្ស៊ិ (TAKAHASHI Akemi) នាយិកា មូលនិធិសម្រាប់ការអភិវឌ្ឍន៍ និងជំនួយសង្គ្រោះអន្តរជាតិ (FIDR)**
- **សូមគោរព អស់លោក លោកស្រី!**

ជាបឋមខ្ញុំសូមសំដែងនូវមរណៈទុក្ខដ៏ក្រៀមក្រំជាមួយព្រះញាតិវង្សានុវង្ស រាជរដ្ឋាភិបាល និងប្រជាជននៃព្រះរាជាណាចក្រកម្ពុជាចំពោះការយាងចូលព្រះទីវង្គតនៃព្រះករុណា ព្រះបាទ សម្តេចព្រះ **នរោត្តម សីហនុ** ព្រះបិតាឯករាជ្យជាតិខ្មែរ។

ថ្ងៃនេះ យើងបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយជាមួយFIDRសម្រាប់គម្រោងពង្រីកអគារវះកាត់ក្នុងមន្ទីរពេទ្យកុមារជាតិ។

ការកែលម្អស្ថានភាពសុខាភិបាលមិនត្រឹមតែមានសារៈសំខាន់សម្រាប់ការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាពប៉ុណ្ណោះទេ តែក៏ជាផ្នែកដ៏សំខាន់មួយសម្រាប់វិស័យមនុស្សធម៌ផងដែរ។ ជាងនេះទៅទៀត ការកែលម្អសេវាសុខាភិបាលសម្រាប់កុមារ រឹតតែមានសារៈសំខាន់ ព្រោះវាជាការវិនិយោគទៅលើកុមារដែលនឹងក្លាយជាអ្នកដឹកនាំប្រទេសនាពេលអនាគត។ ផែនការយុទ្ធសាស្រ្តសម្រាប់វិស័យសុខាភិបាលឆ្នាំ២០០៨-២០១៥ក៏បានផ្តល់អាទិភាពខ្ពស់ទៅលើការកែលម្អសេវាសុខាភិបាលសម្រាប់កុមារផងដែរ។

ក្នុងនាមជាប្រទេសផ្តល់ជំនួយធំបំផុតមួយ រដ្ឋាភិបាលជប៉ុនតែងតែផ្តល់ជំនួយឧបត្ថម្ភសម្រាប់វិស័យជាច្រើនដើម្បីគាំទ្រដល់កសាង និងអភិវឌ្ឍន៍ប្រទេសកម្ពុជាតាំងពីឆ្នាំ១៩៩២។ ចំពោះការគាំទ្រទៅលើវិស័យសុខាភិបាល រដ្ឋាភិបាលជប៉ុនបានរួមចំណែកតាមរយៈការកែលម្អហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល តួយ៉ាងមជ្ឈមណ្ឌលជាតិគាំពារសុខភាពមាតានិងទារកនិងការអភិវឌ្ឍធនធានមនុស្សជាដើម។

ក្រោមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងការឧបត្ថម្ភគាំទ្រពីសហគមន៍អ្នកផ្តល់ជំនួយដែលរួមមានរដ្ឋាភិបាលជប៉ុនផងនោះ អត្រាមរណៈមាតានិងទារកក្នុងប្រទេសកម្ពុជាបានថយចុះជាលំដាប់ក្នុងប៉ុន្មានឆ្នាំចុងក្រោយនេះ។ទោះជាយ៉ាងណាក៏ដោយ បើប្រៀបធៀបទៅនឹងប្រទេសជិតខាង ប្រទេសកម្ពុជានៅតែស្ថិតក្នុងលំដាប់ទាបក្នុងការកែលម្អសេវាសុខាភិបាល។ ចាប់តាំងពីការកែលម្អសេវាសុខាភិបាលសម្រាប់កុមារត្រូវបានទទួលស្គាល់ថាជាបញ្ហាបន្ទាន់មួយមក រាជរដ្ឋាភិបាលកម្ពុជា សហគមន៍អ្នកផ្តល់ជំនួយ និងអង្គការក្រៅរដ្ឋាភិបាលបានសហការគ្នាយ៉ាងស្អិតរមួត និងជួយបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមកដើម្បីកែលម្អស្ថានភាពសុខភាពកុមារក្នុងប្រទេសកម្ពុជា។

អង្គការFIDR ដែលជាអង្គការក្រៅរដ្ឋាភិបាលមួយរបស់ជប៉ុន បានចាប់ផ្តើមការគាំទ្ររបស់ខ្លួនដល់អគារវះកាត់កុមារនៃមន្ទីរពេទ្យកុមារជាតិចាប់ពីឆ្នាំ១៩៩៦។FIDRបានជួយកែលម្អហេដ្ឋារចនាសម្ព័ន្ធវះកាត់ បំពាក់សម្ភារៈបរិក្ខារពេទ្យទំនើបៗ និងផ្តល់ការបណ្តុះបណ្តាលបច្ចេកទេសដល់អ្នកជំនាញសុខាភិបាល។ ជាលទ្ធផល មន្ទីរពេទ្យកុមារជាតិបានក្លាយជាមជ្ឈមណ្ឌលបង្គោលសម្រាប់ការវះកាត់កុមារ ក៏ដូចជាបានពង្រឹងសមត្ថភាពខ្លួនជាវិទ្យាស្ថានបណ្តុះបណ្តាលមួយផងដែរ។

ខ្ញុំបានដឹងថាគម្រោងដែលនឹងត្រូវអនុវត្តដោយFIDRក្នុងឆ្នាំនេះមានគោលបំណងកែលម្អសេវាសុខាភិបាល និង បង្កើនសមត្ថភាពបណ្តុះបណ្តាលរបស់អគារវះកាត់ក្នុងមន្ទីរពេទ្យកុមារជាតិបន្ថែមពីលើការគាំទ្រទៅលើផ្នែកវះកាត់កុមារដែលFIDRបានធ្វើកន្លងមក។ ខ្ញុំសង្ឃឹមថា តាមរយៈគម្រោងនេះ មិនត្រឹមតែសេវាសុខាភិបាលនៅក្នុងមន្ទីរពេទ្យកុមារជាតិ ប៉ុន្តែសេវាសុខាភិបាលនៅក្នុងមន្ទីរពេទ្យខេត្តនានាក៏នឹងប្រសើរឡើងផងដែរ ហើយអ្នកជំងឺផ្នែកវះកាត់ដែលជាកុមារប្រមាណ១០,០០០នាក់នឹងអាចទទួលបានសេវាដែលមានគុណភាពខ្ពស់នៅតាមមន្ទីរពេទ្យទាំងនោះ។

ជាចុងក្រោយនេះ ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនគឺដើម្បីគាំទ្រដល់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុនក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីជួយដល់ការអភិវឌ្ឍន៍ និងស្ថាបនាប្រទេសនៅតាមកំរិតមូលដ្ឋាន។ ខ្ញុំសូមជូនពរឲ្យការអនុវត្តគម្រោងនេះទទួលបានជោគជ័យ ហើយខ្ញុំសង្ឃឹមថាកិច្ចសហប្រតិបត្តិការនេះនឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

សូមអរគុណ!